**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី**

លេខ.........✓......... កកន

# សេចក្តីជូនដំណឹង
## ពិធីសម្ពោធ និងដាក់ឱ្យដំណើរការជាផ្លូវការ
## «មជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគ្រិនភាពស្ត្រី»

ថ្ងៃពុធ ១៣កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥

ក្រសួងកិច្ចការនារី មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនមេត្តាជ្រាបថា ក្រសួងកិច្ចការនារី នឹងរៀបចំ **ពិធីសម្ពោធនិងដាក់ឱ្យដំណើរការជាផ្លូវការ «មជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគ្រិនភាពស្ត្រី (ម.ស.ស.ស.)» នៅថ្ងៃពុធ ១៣កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង៨:៣០នាទីព្រឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ បណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត។** ពិធីនេះនឹងមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំជាន់ខ្ពស់ តំណាងក្រសួង-ស្ថាប័ន តំណាងស្ថានទូត ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល សហគ្រិន និងអាជីករជាស្ត្រី មន្ទីរកិច្ចការនារីរាជធានី ខេត្ត មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងដៃគូពាក់ព័ន្ធ សរុបប្រមាណ១៥០០នាក់ (ចូលរួមដោយផ្ទាល់ប្រមាណ៥០០នាក់ និងតាមប្រព័ន្ធអនឡាញប្រមាណ១០០០នាក់)។

**សម្រាប់សាធារណៈជន** មជ្ឈមណ្ឌលនឹងបើកជូនចូលទស្សនាដោយសេរីនៅក្នុងបរិវេណមជ្ឈមណ្ឌល ព្រមទាំងមានការតាំងពិព័រណ៍លក់ផលិតផល និងសេវាកម្មអាជីវកម្មដែលដឹកនាំ និងគ្រប់គ្រងដោយស្ត្រីនៅកម្ពុជា ដែលជាដៃគូរបស់មជ្ឈមណ្ឌល ដែលមានរយៈពេល៣ថ្ងៃ ***ចាប់ពីរសៀលថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥***។

ដំណើរការរបស់ ម.ស.ស.ស. គឺជាអភិក្រមថ្មីមួយបន្ថែមទៀតរបស់ក្រសួងកិច្ចការនារី ដើម្បីបង្កើតប្រព័ន្ធអេកូស៊ី (Ecosystem) រួមមួយសម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសហគ្រិនភាពស្ត្រី រួមចំណែកអភិវឌ្ឍមូលធនមនុស្ស ជាពិសេសមូលធនស្ត្រី ឱ្យចូលរួមប្រកបដោយភាពបុរេសកម្ម គុណតម្លៃ និងមានសក្តានុពលពេញលេញ នៅក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

ម.ស.ស.ស. មានកម្មវិធីជាយុទ្ធសាស្ត្រ ចំនួន៤៖

១. **កម្មវិធីអភិវឌ្ឍសមត្ថភាពសេដ្ឋកិច្ចដល់ស្ត្រី** តាមរយៈការបណ្តុះបណ្តាល បង្វឹកណែនាំលើការបណ្តុះសហគ្រិនភាព ភាពជាអ្នកដឹកនាំក្នុងវិស័យសេដ្ឋកិច្ច និងជំនាញឌីជីថលជាដើម។

២. **កម្មវិធីគាំទ្រការចាប់ផ្តើមនិងអភិវឌ្ឍអាជីវកម្ម** ជាពិសេសសម្រាប់ស្ត្រីវ័យក្មេង និងអាជីវករស្ត្រី។

៣. **កម្មវិធីសិក្សាស្រាវជ្រាវ និងនវានុវត្តន៍** ដោយផ្តោតលើតម្រូវការ និងនិន្នាការថ្មីៗផ្នែកសេដ្ឋកិច្ចនិងយេនឌ័រ។

៤. **ការពង្រីកបណ្តាញនិងទីផ្សារ** ក្នុងស្រុក តំបន់និងសកល សម្រាប់សហគ្រិន និងអាជីករជាស្ត្រី ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖ ទូរស័ព្ទ ០១១ ៥៦៣ ៦៣៦ ឬ០៧៧ ៤៣២ ៣០៤ ឬអ៊ីម៉ែល sopheakrany777@gmail.com

ថ្ងៃព្រហស្បតិ៍ ៧កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥